ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្តាល
THE ARBITRATION COUNCIL

លេខ និង ឈ្មោះសំណុំរឿង ៖ ១១០/១១-ស៊ីម៉ាណូ
កាលបរិច្ឆេទនៃសេចក្តីបង្គាប់ ៖ ថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០១១

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា៣១៣នៃច្បាប់ស្តីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជកៈ អ៊ឹង សុទ្ធី

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិតៈ វ៉ែន ពៅ

ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើៈ ប៉ែន ប៊ុនឈា

## ភាគីនៃវិវាទ

### ១- ភាគីនិយោជក

ឈ្មោះ ៖ ក្រុមហ៊ុន ស៊ីម៉ាណូ (ខេមបូឌា)

អាសយដ្ឋាន ៖ ភូមិត្រពាំងរកា ឃុំត្រពាំងគង ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ

ទូរស័ព្ទ ៖ ០១២ ៩៣៥ ១០៩ ទូរសារ ៖ គ្មាន

តំណាងភាគីនិយោជក ៖

១- លោក តូច ម៉ានីន ប្រធានរដ្ឋបាល

២- លោក គង គឿន ចាត់ការទូទៅ

### ២- ភាគីកម្មករនិយោជិត

ឈ្មោះ ៖ - សហជីពសេរីកម្មករនៃព្រះរាជាណាចក្រកម្ពុជា

- សហជីពសេរីកម្មករ នៃរោងចក្រ ស៊ីម៉ាណូ

អាសយដ្ឋាន ៖ ភូមិត្រពាំងរការ ឃុំត្រពាំងគង ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ

ទូរស័ព្ទ ៖ ០១២ ៩៣៥ ៤៩៦ ទូរសារ ៖ គ្មាន

តំណាងកម្មករនិយោជិតៈ

១- លោក យ៉ាន់ រ័ត្នកែវពិសី មន្ត្រីដោះស្រាយវិវាទរបស់សហជីពសេរីកម្មករ នៃព្រះរាជាណាចក្រកម្ពុជា



ផ្ទះលេខ ៧២ ផ្លូវលេខ ៥៩២ (កែងផ្លូវលេខ ៣២៧) សង្កាត់បឹងកក់ ២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។ ទូរស័ព្ទ/ទូរសារៈ ៨៥៥-២៣ ៨៨១ ៨២៤
No. 72, Street 592 (corner of St. 327), Sangkat Boeung Kak II, Khan Tuol Kork, Phnom Penh◆ Tel/Fax: 855-23 881 824
E-mail: secretariat@arbitrationcouncil.org◆ Website: www.arbitrationcouncil.org

២- កញ្ញា ជិន បុប្ផា | អនុប្រធានក្រុម
៣- កញ្ញា ឃុន ចាន់ណា | កម្មករ
៤- លោក ជឹម ភារៈ | ប្រធានក្រុម
៥- កញ្ញា ហ៊ុំ ស្រីល័ក្ខ | ប្រធានក្រុម
៦- កញ្ញា ឃុន សុភ័ស | អនុប្រធានក្រុម
៧- កញ្ញា កុប គន្ធា | កម្មករ
៨- លោក ឃន ប៉ាន | ប្រធាន QC
៩- កញ្ញា ឈុន សុភា | កម្មករ
១០- លោក ឡុង ពៅ | អនុប្រធានក្រុម
១១- លោក ភួង ឡឿន | កម្មករ

## បញ្ហាក្តីវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

១- ភាគីសហជីព សុំឱ្យក្រុមហ៊ុនបញ្ឈប់ការរើសអើងសហជីព ។

២- សុំឱ្យក្រុមហ៊ុនទទួលយកកម្មករទាំងបីនាក់ដែលក្រុមហ៊ុនបានបញ្ឈប់ពីការងារ ឱ្យចូលធ្វើការងារជាធម្មតាវិញ ហើយប្រាក់ដែលក្រុមហ៊ុនបានផ្តល់ជាសំណងក្នុងពេលបញ្ឈប់ពីការងារនោះ យើងខ្ញុំទាំងបីនាក់មិនឱ្យវិញទេ ដោយចាត់ទុកថា ជាការទូទាត់សងការខូចខាតកិត្តិយសពេលបញ្ឈប់ពីការងារ ។

៣- ក្នុងករណីក្រុមហ៊ុនមិនព្រមទទួលយកពួកយើងទាំងបីឱ្យចូលបំរើការងារទេនោះ យើងទាំងបីនាក់ សុំឱ្យក្រុមហ៊ុនទូទាត់សំណង ក្នុងម្នាក់ ៣០០០ ដុល្លារ (បីពាន់ដុល្លារ) ។

ក្រោយការផ្សះផ្សាមិនសះជានឹងគ្នាហើយនោះ ភាគីសហជីពកម្មករបានជូនដំណើងស្តីពីការធ្វើកូដកម្មដើម្បីទាមទារលក្ខណ្ឌខាងលើ ។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែកទីពីរ (ខ)(មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល លេខ ០៩៩ សកបយ ចុះថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាស លេខ ០៩៩ សកបយ ចុះថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០០៤ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ១៣៦ កប/ប្រក ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១១ (អាណត្តិទី៥) ។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី ២ (ក) នៃច្បាប់ស្តីពីការងារ ។ ប៉ុន្តែការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ

ហើយរបាយការណ៍ស្តីអំពីការមិនសះជា លេខ ៧១៨ របក/កស្ត ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១១ ត្រូវបានបញ្ជូនមក លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី២២ ខែសីហា ឆ្នាំ២០១១។

**សវនាការ និង សង្ខេបនីតិវិធី**

ទីកន្លែងសវនាការ ៖ ក្រុមប្រឹក្សាអាជ្ញាកណ្តាល "ភូមិគ្រឹះលេខ ៧២ ផ្លូវលេខ ៥៩២ កាច់ជ្រុងផ្លូវលេខ ៣២៧ (ទល់មុខវិទ្យាល័យតន្រ្តីទេវី) សង្កាត់បឹងកក់២ ខណ្ឌទួលគោក រាជធានីភ្នំពេញ។

កាលបរិច្ឆេទជួបប្រជុំមុនសវនាការ ៖ ថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២០១១ (វេលាម៉ោង ២៖០០ នាទី រសៀល)។

បញ្ហានៃនីតិវិធី ៖

នៅថ្ងៃទី១១ ខែសីហា ឆ្នាំ២០១១ មន្ទីរការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកំពង់ស្ពឺ បានទទួលបណ្តឹងមួយរបស់សហជីពសេរីកម្មករនៃព្រះរាជាណាចក្រកម្ពុជា ដែលបានប្តឹងក្រុមហ៊ុន ស៊ីម៉ាណូ (ខេមបូឌា) ខូអិលធីឌី ដោយចោទថា ក្រុមហ៊ុននេះមិនគោរពច្បាប់ស្តីពីការងារ និងរើសអើងសហជីព។ ក្រោយពីបានទទួលបណ្តឹងនេះភ្លាម នៅថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១១ មន្ទីរបានចាត់តាំងអញ្ជើញភាគីទាំងពីរផ្តល់ព័ត៌មាន និងឈានទៅធ្វើការផ្សះផ្សា។ នៅថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១១ វេលាម៉ោង ប្រាំបួនព្រឹក មន្ទីរបានរៀបចំការផ្សះផ្សា ប៉ុន្តែ ភាគីក្រុមហ៊ុន មិនបានចូលរួមផ្សះផ្សា ដោយបានចាត់ទុកថា មិនទទួលស្គាល់សហជីពនេះទេ ព្រោះកន្លងមក ក្រុមហ៊ុនមិនទាន់បាន ទទួលឯកសារណាមួយពីសហជីពមួយនេះឡើយ។ ក្រោយពេលមិនមកចូលរួមផ្សះផ្សាពីភាគីក្រុមហ៊ុននោះ ភាគីកម្មករ និងសហជីពដើរចេញពីតុចរចា និងមិនបានចូលរួមពិភាក្សាពីការចាត់វិធានការបន្តនោះទេ ដូចនេះ ការផ្សះផ្សា មិនទទួលបានការសះជានឹងគ្នាទេ។

ក្រោយពីទទួលរបាយការណ៍មិនសះជារបស់ មន្ទីរការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកំពង់ស្ពឺ លេខាធិការដ្ឋាន ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានទទួលដំណឹងថា ភាគីកម្មករនិយោជិតនៅតែបន្តធ្វើកូដកម្មដដែល។ នៅថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១១ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានចេញបញ្ជាឱ្យភាគីកម្មករនិយោជិតផ្អាកជាបន្ទាន់ នូវការធ្វើកូដកម្មរបស់កម្មករនិយោជិតនៅក្រុមហ៊ុន ស៊ីម៉ាណូ (ខេមបូឌា) រហូតដល់នីតិវិធីអាជ្ញាកណ្តាល ត្រូវបាន បញ្ចប់សព្វគ្រប់តាមនីតិវិធីច្បាប់ ហើយកូដករទាំងអស់ត្រូវត្រឡប់ចូលធ្វើការវិញ ចាប់ពីថ្ងៃទី២៥ ខែសីហា ឆ្នាំ ២០១១ តាមវេនរបស់ខ្លួន។ បន្ទាប់ពីចេញសេចក្តីបញ្ជានេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានទទួលដំណឹង តាមរយៈ លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលថា ភាគីកម្មករនិយោជិតមិនបានត្រឡប់ចូលធ្វើការតាមសេចក្តីបញ្ជានោះ ទេ ហើយនៅតែបន្តធ្វើកូដកម្មដដែល។

បន្ទាប់ពីទទួលដំណឹងពីការបន្តធ្វើកូដកម្មរបស់កម្មករនិយោជិតមក ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានឱ្យលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលអញ្ជើញភាគីកម្មករនិយោជិត និងភាគីនិយោជក មកជួបប្រជុំមុនថ្ងៃសវនាការ នៅថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១១។ ភាគីនិយោជក និងភាគីកម្មករនិយោជិតមានវត្តមាន តាមការកោះអញ្ជើញរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល។ នៅក្នុងការជួបប្រជុំមុនថ្ងៃសវនាការនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានសាកសួរភាគីអំពីបញ្ហាការឈប់ធ្វើកូដកម្មរបស់ភាគីកម្មករនិយោជិត និងការអនុញ្ញាតរបស់ភាគីនិយោជកឱ្យកម្មករនិយោជិត

ទាំងអស់ចូលធ្វើការវិញតាមវេនរៀង១ខ្លួន។ ភាគីកម្មករនិយោជិតបញ្ជាក់ជំហរថា កម្មករនិយោជិតនឹងមិនបញ្ឈប់កូដកម្មទេ លុះត្រាតែ និយោជកអនុញ្ញាតឱ្យថ្នាក់ដឹកនាំសហជីពដែលនិយោជកបានបញ្ឈប់ពីការងារនោះ ឱ្យចូលធ្វើការធម្មតាវិញ។ ចំណែកឯភាគីនិយោជកវិញបញ្ជាក់ថា គាត់អនុញ្ញាតឱ្យកូដករទាំងអស់ចូលធ្វើការវិញតាមវេនរបស់ខ្លួន លើកលែងតែ ថ្នាក់ដឹកនាំសហជីពទាំងបីនាក់នោះ។

នៅថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១០ សហភាពសហជីព សហព័ន្ធសហជីព និងសហជីព ចំនួន ៦ និងប្រធានសមាគមរោងចក្រកាត់ដេរនៅកម្ពុជាបានចុះហត្ថលេខាលើអនុស្សារណៈ នៃការយោគយល់គ្នា ស្តីពីការធ្វើឱ្យប្រសើរឡើងនូវទំនាក់ទំនងវិជ្ជាជីវៈក្នុងឧស្សាហកម្មកាត់ដេរ សំលៀកបំពាក់ ក្នុងការយល់ព្រមទទួលយកសេចក្តីបង្គាប់ជាប់កាតព្វកិច្ចចំពោះវិវាទអំពីសិទ្ធិ។ នៅក្នុងសំណុំរឿងនេះ សហជីពសេរីកម្មករនៃព្រះរាជាណាចក្រកម្ពុជា និង ក្រុមហ៊ុន ស៊ីម៉ាណូ នៃសំណុំរឿងនេះ គឺជាភាគីនៃអនុសារណៈនេះ ដែលត្រូវបានលើកទឹកចិត្តឱ្យដោះស្រាយវិវាទដោយសន្តិវិធី ហើយអាចធ្វើកូដកម្ម ឬ ឡុកអៅ បាន នៅចុងក្រោយបំផុត បន្ទាប់ពីនីតិវិធីដោះស្រាយវិវាទដោយសន្តិវិធីបានបញ្ចប់សព្វគ្រប់។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានព្យាយាមធ្វើការផ្សះផ្សាភាគីទាំងពីរ ហើយស្នើឱ្យកូដករទាំងអស់ចូលធ្វើការវិញតាមវេនរៀង១ខ្លួន លើកលែងតែ ថ្នាក់ដឹកនាំសហជីពទាំងបីដែលនិយោជកបានបញ្ឈប់រួចហើយ ដើម្បីទុកលទ្ធភាពឱ្យក្រុមប្រឹក្សាអាជ្ញាកណ្តាលបន្តនីតិវិធីដោះស្រាយវិវាទទាំងនេះ តាមច្បាប់ស្តីពីការងារ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានទុកពេលបន្ថែមទៀតឱ្យភាគីកម្មករនិយោជិត ដែលជាកូដករទាំងអស់ចូលធ្វើការវិញសិន លើកលែងតែ ថ្នាក់ដឹកនាំសហជីពទាំងបីនាក់នោះ រហូតមកដល់ថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១១។

ប៉ុន្តែមកដល់ថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១១ លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល បានទទួលដំណឹងពីភាគីទាំងពីរថា កម្មករនិយោជិតមិនត្រឡប់ចូលធ្វើការទេ ពោល គឺនៅតែបន្តធ្វើកូដកម្ម ចំណែកឯនិយោជកនៅតែមិនព្រមអនុញ្ញាតឱ្យថ្នាក់ដឹកនាំសហជីពទាំងបីនាក់ចូលធ្វើការវិញ ជាមួយនឹងហ្វូងកូដករដែរ។

ហេតុនេះហើយ នៅក្នុងរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណាដូចខាងក្រោមៈ

**ភស្តុតាង**

សាក្សី និង អ្នកជំនាញក្រៅពីភាគី ៖ គ្មាន

**ឯកសារ ភស្តុតាង ដែលក្រុមអាជ្ញាកណ្តាលយកមកពិចារណាមាន**

ក- ឯកសារបានទទួលពីភាគីនិយោជក ៖

១- លិខិតផ្ទេរសិទ្ធិរបស់នាយកក្រុមហ៊ុន ស៊ីម៉ាណូ (ខេមបូឌា) ផ្ទេរសិទ្ធិជូន លោក តូច ម៉ានីន ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១១ ។

២- លិខិតរបស់នាយកក្រុមហ៊ុន ស៊ីម៉ាណូ (ខេមបូឌា) ខូអិលធីឌី គោរពជូន លោកប្រធានក្រុមប្រឹក្សាអាជ្ញាកណ្តាល ស្តីពីសំណើសុំចេញសេចក្តីបញ្ជាផ្អាកសកម្មភាពធ្វើកូដកម្មរបស់កម្មករនិយោជិត នៃក្រុមហ៊ុន ស៊ីម៉ាណូ (ខេមបូឌា) ខូអិលធីឌី ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១១ ។

ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត ៖ គ្មាន

គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន ស៊ីម៉ាណូ (ខេមបូឌា) ខូអិលធីឌី លេខ ៧១៨ របក/កស្ក ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១១ ។

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមនៅក្រុមហ៊ុន ស៊ីម៉ាណូ (ខេមបូឌា) ខូអិលធីឌី ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១១ ។

ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល

១- លិខិតរបស់លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល ជំរាបជូន ប្រធានសហជីពសេរីកម្មករនៃក្រុមហ៊ុន ស៊ីម៉ាណូ (ខេមបូឌា) ស្តីពីការជ្រើសរើសអាជ្ញាកណ្តាល លេខ ៦១៥ កប/អក/វក/លកអ. ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១១ ។

២- លិខិតអញ្ជើញភាគីនិយោជកចូលរួមផ្តល់ព័ត៌មានមុនសវនាការ លេខ ៦២២ កប/អក/វក/លកអ. ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១១ ។

៣- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមផ្តល់ព័ត៌មានមុនសវនាការ លេខ ៦២៣ កប/អក/វក/លកអ. ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១១ ។

**អង្គហេតុ**

មិនមានការរកឃើញអង្គហេតុទាក់ទងទៅនឹងចំណុចវិវាទ នៅក្នុងរបាយការណ៍មិនសះជា ដែលក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាលទេ ដោយសារសវនាការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលមិនអាចដំណើរការទៅបាន។

**ហេតុផលនៃសេចក្តីសម្រេច**

យោងតាមប្រការ ២០ នៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ស្តីពី ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានចែងថា *"ក្នុងអំឡុងពេលនៃដំណើរការរបស់ក្រុមអាជ្ញាកណ្តាល ភាគីវិវាទទាំងឡាយ ត្រូវផ្អាករាល់វិធានការវិវាទ ដូចជា កូដកម្ម ឬឡុកអៅ (ដូចមានចែងក្នុងមាត្រា ៣១៨ នៃច្បាប់ស្តីពីការងារ) ឬវិធានការដទៃទៀត ដែលអាចធ្វើឱ្យស្ថានភាពវិវាទកាន់តែធ្ងន់ធ្ងរ។ ភាគីទាំងនេះត្រូវតែចូលរួមគ្រប់កិច្ចប្រជុំទាំងឡាយ ដែលក្រុមអាជ្ញាកណ្តាលបានអញ្ជើញឱ្យចូលរួម។"*

បន្ថែមលើនេះទៀត នៅក្នុងសេចក្តីបញ្ញមុនៗ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានបកស្រាយមាត្រានេះថា ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងមិនបន្តដំណើរការអាជ្ញាកណ្តាលទេ នៅពេលណាភាគីកម្មករនិយោជិតកំពុងធ្វើកូដកម្ម ឬនិយោជកធ្វើឡុកអៅ។ (សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ *៥៩/០៦-សាង វ៉ី លេខ៣៩/០៨-ចុង យ៉ើ* *និងលេខ ១៣៧/០៩ និង ១៣៨/០៩-ញូ ភាញ់*)។

ទាក់ទងនឹងការធ្វើកូដកម្មរបស់កម្មករនិយោជិត នៅក្នុងពេលដំណើរការក្រុមប្រឹក្សាអាជ្ញាកណ្តាលនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលក្នុងសំណុំរឿងនេះ បានរកឃើញយុត្តិសាស្ត្ររបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅក្នុងសំណុំរឿងមុនៗ ដូចខាងក្រោមៈ

នៅក្នុងសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ ០៤/០៤-អិម អេស អាយ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានចេញសេចក្តីជូនដំណឹងមួយ ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០០៤ ដែលកថាខ័ណ្ឌទី៤ នៃសេចក្តីជូនដំណឹងនេះ ចែងថា “*ដោយពិនិត្យឃើញថា ភាគីនៃវិវាទការងារនេះមិនមានសិទ្ធិធ្វើកូដកម្ម ក្នុងកំឡុងពេលនៃដំណើរការរបស់អាជ្ញាកណ្តាល ក្រុមប្រឹក្សាអាជ្ញាកណ្តាលមិនអាចធ្វើការដោះស្រាយ ឬក៏ចេញសេចក្តីបង្គាប់លើវិវាទការងាររួម ដែលបានបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាលនេះឡើយ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលអាចដោះស្រាយវិវាទការងាររួមនេះម្តងទៀតបាន នៅពេលណាដែលសហជីពកម្មករនិយោជិតទាំងអស់ឈប់ធ្វើកូដកម្ម។*”

នៅក្នុងសំណុំរឿងលេខ ៧៧/០៥-ហ្វ្រង់កូ នីតធីង ហ្គាមេន ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានចេញសេចក្តីបញ្ជាចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០០៥ ហើយបានចែងនៅក្នុងចំណុចទី៤ ថា “ *នៅក្នុងករណីដែលភាគីកម្មករនិយោជិតបន្តធ្វើកូដកម្ម ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងមិនដំណើរការដោះស្រាយវិវាទការងាររួមនេះទេ។*“

នៅក្នុងសំណុំរឿងលេខ ២៨/០៦-ជី ឌី អឹម និង សំណុំរឿងលេខ ៣៤/០៦-ហ្គោល ហ្វេម ក្រុមប្រឹក្សាអាជ្ញាកណ្តាល ក៏បានចេញសេចក្តីបង្គាប់បិទសំណុំរឿងទាំងនោះ ដោយមូលហេតុថា កម្មករនិយោជិតនៅតែបន្តធ្វើកូដកម្មក្នុងអំឡុងពេលដំណើរការនីតិវិធីរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល (សូមមើលបន្ថែមក្នុងសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ *៩៧/០៧-ស៊ូត វ៉េ, លេខ ៦៣/០៨-សៅធន៍ ប៉េរ និង ហ្គោលដិន ហ្វ្រេន និង លេខ ១០៣/១០-វ៉ាយថិថ*)។

ផ្អែកលើការបកស្រាយខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា នៅក្នុងសំណុំរឿងលេខ ១១០/១១-ស៊ីម៉ាណូ (ខេមបូឌា) នេះ ភាគីកម្មករនិយោជិតដែលជាកូដករទាំងអស់នៅតែបន្តធ្វើកូដកម្ម ពោលគឺ មិនគោរពតាមសេចក្តីបញ្ជា និងការស្នើរសុំរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលទេ។

ហេតុដូច្នេះ ដោយផ្អែកទៅលើច្បាប់ ព្រមទាំងសេចក្តីបង្គាប់របស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងមុនៗ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចថា មិនបន្តដំណើរការអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងនេះទេ។

យោងតាមហេតុផលខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេច ដូចតទៅ ៖

## សម្រេច និង បង្គាប់

មិនបន្តដំណើរការអាជ្ញាកណ្តាលក្នុងសំណុំរឿងលេខ ១១០/១១-ស៊ីម៉ាណូ (ខេមបូឌា)។

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្តាល**

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីនិយោជក ៖

ឈ្មោះ ៖ **អ៊ុំង សុន្ធី**

ហត្ថលេខា: ----------------------------------

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីកម្មករនិយោជិត ៖

ឈ្មោះ ៖ **វ៉ែន ពៅ**

ហត្ថលេខា: --------------------------------

ប្រធានក្រុមអាជ្ញាកណ្តាល ៖

ឈ្មោះ ៖ **ម៉ែន ម៉ុនឈា**

ហត្ថលេខា: --------------------------------